**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ:..១១៤..អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រង នៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាននិងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៥

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះមានគោលបំណងលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង ការបំពេញមុខងារ ការកំណត់គណនេយ្យភាព និងការទទួលខុសត្រូវនៅតាមកម្រិតឋានានុក្រមនៃមុខតំណែងនីមួយៗក្នុងមុខងារសាធារណៈ។

**មាត្រា២ ._**

អនុក្រឹត្យនេះមានគោលដៅដើម្បី៖

- ធានាឱ្យមានសង្គតិភាពនៃរចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រសួង ស្ថាប័ននៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- កំណត់ចំនួនអតិបរមានៃមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងចាប់ពីមុខតំណែងគ្រប់គ្រងខ្ពស់បំផុតរហូតដល់មុខតំណែងគ្រប់គ្រងទាបបំផុតក្នុងមុខងារសាធារណៈ
- កំណត់បន្ទាត់គណនេយ្យភាពនិងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នក្នុងការគ្រប់គ្រងនិងរៀបចំរចនាសម្ព័ន្ធព្រមទាំងការតែងតាំងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រសួង ស្ថាប័ននៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

**មាត្រា៣ ._**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះគ្រប់រចនាសម្ព័ន្ធគ្រប់គ្រង និង មុខតំណែងគ្រប់គ្រងក្នុងមុខងារសាធារណៈស្ថិតក្រោមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជាដែលរួមមានមុខតំណែងជាប្រធាននិងអនុប្រធានឬមុខតំណែងកម្រិតប្រហាក់ប្រហែលដែលគ្រប់គ្រងអង្គភាពចំណុះក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

អនុក្រឹត្យនេះមិនមានវិសាលភាពអនុវត្តចំពោះរចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងគ្រប់គ្រងរបស់នគរបាលជាតិ កងយោធពលខេមរភូមិន្ទ និងរចនាសម្ព័ន្ធស្ថានតំណាងរបស់ព្រះរាជាណាចក្រកម្ពុជាប្រចាំនៅបរទេសឡើយ។

## ជំពូកទី២

## ការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រង

**មាត្រា៤ ._**

រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រសួង ស្ថាប័ននៅថ្នាក់ជាតិ មានដូចខាងក្រោម៖

- រចនាសម្ព័ន្ធគ្រប់គ្រងនិងថ្នាក់ប្រហាក់ប្រហែលរួមមាន៖
  - អគ្គលេខាធិការដ្ឋាន/អគ្គនាយកដ្ឋាន/អគ្គាធិការដ្ឋាន
  - នាយកដ្ឋាន/អធិការដ្ឋាន
  - ការិយាល័យ
  - អង្គភាពថ្នាក់ក្រោមការិយាល័យ។
- មុខតំណែងគ្រប់គ្រងនិងថ្នាក់ប្រហាក់ប្រហែលរួមមាន៖
  - អគ្គលេខាធិការ/អគ្គនាយក/អគ្គាធិការ
  - អគ្គលេខាធិការរង/អគ្គនាយករង/អគ្គាធិការរង
  - ប្រធាននាយកដ្ឋាន/អធិការនៃអធិការដ្ឋាន
  - អនុប្រធាននាយកដ្ឋាន/អធិការរង
  - ប្រធានការិយាល័យ
  - អនុប្រធានការិយាល័យ
  - មុខតំណែងថ្នាក់ក្រោមអនុប្រធានការិយាល័យ។

រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់ស្ថាប័ននៅថ្នាក់ក្រោមជាតិមានដូចខាងក្រោម៖

- រចនាសម្ព័ន្ធគ្រប់គ្រងកម្រិតរាជធានី ខេត្ត រួមមាន៖
  - សាលារាជធានី ខេត្ត
  - លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង
  - មន្ទីរនិងអង្គភាពជំនាញ
  - ការិយាល័យ
  - អង្គភាពថ្នាក់ក្រោមការិយាល័យ។
- មុខតំណែងគ្រប់គ្រងនិងថ្នាក់ប្រហាក់ប្រហែលកម្រិតរាជធានី ខេត្ត រួមមាន៖
  - អភិបាលនៃគណៈអភិបាល
  - អភិបាលរងនៃគណៈអភិបាល
  - ប្រធានលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង
  - នាយករដ្ឋបាល
  - ប្រធានមន្ទីរ/នាយករងរដ្ឋបាល/អនុប្រធានលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង
  - នាយកទីចាត់ការ/ប្រធានអង្គភាពលទ្ធកម្ម
  - អនុប្រធានមន្ទីរ
  - នាយករងទីចាត់ការ/អនុប្រធានអង្គភាពលទ្ធកម្ម
  - ប្រធានការិយាល័យ
  - អនុប្រធានការិយាល័យ
  - មុខតំណែងថ្នាក់ក្រោមអនុប្រធានការិយាល័យ។
- រចនាសម្ព័ន្ធគ្រប់គ្រងកម្រិតក្រុង ស្រុក ខណ្ឌ រួមមាន៖
  - សាលាក្រុង ស្រុក ខណ្ឌ
  - ការិយាល័យនិងអង្គភាពជំនាញ
  - អង្គភាពថ្នាក់ក្រោមការិយាល័យ។
- មុខតំណែងគ្រប់គ្រងនិងថ្នាក់ប្រហាក់ប្រហែលកម្រិតក្រុង ស្រុក ខណ្ឌ រួមមាន៖
  - អភិបាលនៃគណៈអភិបាល
  - អភិបាលរងនៃគណៈអភិបាល
  - នាយករដ្ឋបាល
  - ប្រធានការិយាល័យ/នាយករងរដ្ឋបាល/ប្រធានអង្គភាពលទ្ធកម្ម
  - អនុប្រធានការិយាល័យ/អនុប្រធានអង្គភាពលទ្ធកម្ម
  - មុខតំណែងថ្នាក់ក្រោមអនុប្រធានការិយាល័យ។
- រចនាសម្ព័ន្ធគ្រប់គ្រង មុខតំណែងគ្រប់គ្រង និងថ្នាក់ប្រហាក់ប្រហែលកម្រិតឃុំ សង្កាត់ រួមមាន៖
  - អង្គភាពជំនាញ
  - ប្រធានអង្គភាពជំនាញ
  - អនុប្រធានអង្គភាពជំនាញ។

**មាត្រា៥ .-**

ការកំណត់រចនាសម្ព័ន្ធមុខតំណែងនិងចំនួនមុខតំណែងគ្រប់គ្រងក្នុងរចនាសម្ព័ន្ធនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ត្រូវផ្អែកលើទំហំការងារ ថវិកា និងចំនួនបុគ្គលិករបស់ក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិនីមួយៗ ដោយចំនួននៃមុខតំណែងគ្រប់គ្រងកម្រិតអនុប្រធានឬថ្នាក់ប្រហាក់ប្រហែលត្រូវកំណត់ដូចខាងក្រោម៖

១- មុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រសួង ស្ថាប័ននៅថ្នាក់ជាតិ

- អគ្គលេខាធិការរង អគ្គនាយករង អគ្គាធិការរង ឬថ្នាក់ប្រហាក់ប្រហែល ត្រូវមានចំនួនយ៉ាងច្រើនបំផុត៥(ប្រាំ)រូប។ ក្នុងករណីមានតម្រូវការចាំបាច់នូវអគ្គលេខាធិការរង អគ្គនាយករង អគ្គាធិការរង ឬថ្នាក់ប្រហាក់ប្រហែល លើសពីចំនួនដែលបានកំណត់ ក្រសួង ស្ថាប័នសាមីត្រូវស្នើសុំការសម្រេចពីនាយករដ្ឋមន្ត្រី
- អនុប្រធាននាយកដ្ឋានឬថ្នាក់ប្រហាក់ប្រហែល ត្រូវមានចំនួនច្រើនបំផុតពី៣(បី)រូបទៅ៥(ប្រាំ)រូប
- អនុប្រធានការិយាល័យឬថ្នាក់ប្រហាក់ប្រហែល ត្រូវមានចំនួនច្រើនបំផុតពី២(ពីរ)រូបទៅ៤(បួន)រូប។

២- មុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៅថ្នាក់ក្រោមជាតិ

- អភិបាលរងនៃគណៈអភិបាល នាយករងរដ្ឋបាល នាយករងទីចាត់ការ អនុប្រធានការិយាល័យនៃសាលារាជធានី ខេត្ត និងអភិបាលរងនៃគណៈអភិបាល នាយករងរដ្ឋបាល អនុប្រធានការិយាល័យក្រុង ស្រុក ខណ្ឌ ត្រូវមានចំនួនអនុលោមបទប្បញ្ញត្តិជាធរមាន
- អនុប្រធានមន្ទីរជំនាញរាជធានី ខេត្តឬថ្នាក់ប្រហាក់ប្រហែល ត្រូវមានចំនួនច្រើនបំផុតត្រឹម៣(បី)រូប
- អនុប្រធានការិយាល័យនៃមន្ទីរជំនាញរាជធានី ខេត្តឬថ្នាក់ប្រហាក់ប្រហែល អនុប្រធានការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ និងអនុប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ត្រូវមានចំនួនច្រើនបំផុតត្រឹម២(ពីរ)រូប
- អនុប្រធានការិយាល័យនៃការិយាល័យជំនាញក្រុង ស្រុក ខណ្ឌឬថ្នាក់ប្រហាក់ប្រហែល ត្រូវមានចំនួន១(មួយ)រូប។

៣- មុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៅតាមវិទ្យាល័យ អនុវិទ្យាល័យ សាលាបឋមសិក្សា និងសាលាមត្តេយ្យសិក្សាសាធារណៈ

- នាយករងវិទ្យាល័យ អនុវិទ្យាល័យ បឋមសិក្សា និងសាលាមត្តេយ្យសិក្សាសាធារណៈ ត្រូវបានកំណត់អនុលោមនិយាមរបស់ក្រសួងអប់រំ យុវជន និងកីឡាដែលមានជាធរមាន ដោយចំនួនអតិបរមានៃមុខតំណែងកម្រិតនាយករងមិនឱ្យលើសពីចំនួន៣(បី)រូប

៤- មុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៅតាមមន្ទីរពេទ្យបង្អែកនិងមណ្ឌលសុខភាព

- អនុប្រធានមន្ទីរពេទ្យបង្អែករាជធានី ខេត្ត ត្រូវមានចំនួនច្រើនបំផុតត្រឹម២(ពីរ)រូប
- អនុប្រធានមន្ទីរពេទ្យបង្អែកក្រុង ស្រុក ខណ្ឌនិងអនុប្រធានមណ្ឌលសុខភាព ត្រូវមានចំនួន១(មួយ)រូប។

ក្រសួង ស្ថាប័ននៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អាចកំណត់ចំនួនមុខតំណែងគ្រប់គ្រងជាក់ស្ដែងនៅតាមក្រសួង ស្ថាប័ន និងអង្គភាពចំណុះ ដោយមានការពិគ្រោះយោបល់ជាមួយក្រសួងមុខងារសាធារណៈនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៣
## ការតែងតាំងឱ្យកាន់មុខតំណែងនិងការបង្កើត ការលុប ការកែសម្រួលរចនាសម្ព័ន្ធនិងមុខតំណែងគ្រប់គ្រង

**មាត្រា៦ .-**

ការតែងតាំងឱ្យកាន់មុខតំណែងគ្រប់គ្រងក្នុងរចនាសម្ព័ន្ធនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិណាមួយ ត្រូវផ្អែកលើមុខតំណែងទំនេរ លក្ខណសម្បត្តិស័ក្តិសមរបស់បេក្ខជនសម្រាប់មុខតំណែង ទំហំការងារ ផលិតភាពការងារ លទ្ធភាពថវិកា និងការធានានូវនិរន្តរភាពការងារក្នុងអង្គភាព។

**មាត្រា៧ .-**

ក្នុងករណីមុខតំណែងប្រធាននៅទំនេរជាស្ថាពរដោយហេតុ ដូចជា មរណភាព ការបោះបង់ការងារជាដើម ប៉ុន្តែពុំទាន់មានការតែងតាំងថ្មី ឬការប្រគល់ភារកិច្ចថ្មី ឬការប្រគល់ភារកិច្ចជាបណ្ដោះអាសន្ន មន្ត្រីរាជការក្នុងអង្គភាពតែមួយដែលមានមុខតំណែងនិងឋានន្តរស័ក្តិខ្ពស់ជាងគេ ត្រូវទទួលបំពេញមុខតំណែងជំនួសជាបណ្ដោះអាសន្ន។ មន្ត្រីរាជការនេះត្រូវបំពេញកាតព្វកិច្ចនៃមុខតំណែងនោះ រហូតដល់មានការតែងតាំងថ្មី។

ក្នុងករណីប្រធានអង្គភាពអវត្តមានដោយហេតុ ដូចជា បេសកកម្មផ្លូវការឬការឈប់សម្រាកស្របតាមបទប្បញ្ញត្តិជាធរមាន ប្រធានអង្គភាពត្រូវប្រគល់សិទ្ធិដល់មន្ត្រីរាជការដែលបំពេញមុខតំណែងគ្រប់គ្រងបន្ទាប់ជាប្រធានស្ដីទី ដើម្បីរក្សានិរន្តរភាពការងារប្រចាំថ្ងៃ លើកលែងតែមានការកំណត់ដោយឡែករបស់រាជរដ្ឋាភិបាលឬក្រសួង ស្ថាប័នសាមី។

**មាត្រា៨ .-**

ការបង្កើត ការលុប និងការកែសម្រួលរចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងពាក់ព័ន្ធចាប់ពីថ្នាក់នាយកដ្ឋានឡើង ទាំងថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងស្ថាប័នសាមី បន្ទាប់ពីទទួលបានការឯកភាពជាមុនពីក្រសួងមុខងារសាធារណៈនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ការបង្កើត ការលុប និងការកែសម្រួលរចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងពាក់ព័ន្ធចាប់ពីថ្នាក់ក្រោមនាយកដ្ឋានចុះទាំងថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួង ស្ថាប័នសាមី បន្ទាប់ពីទទួលបានការឯកភាពជាមុនពីក្រសួងមុខងារសាធារណៈនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៩ .-**

ការបង្កើតក្រុមប្រឹក្សា អាជ្ញាធរ គណៈកម្មាធិការ គណៈកម្មការ ឬអង្គភាពថ្មី ដើម្បីបំពេញបេសកកម្មនិងមុខងារដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ក្រសួង ស្ថាប័នខ្លួន ក្រសួង ស្ថាប័ននោះត្រូវប្រើប្រាស់រចនាសម្ព័ន្ធគ្រប់គ្រងដែលមានស្រាប់របស់ក្រសួង ស្ថាប័នធ្វើជាលេខាធិការដ្ឋាន ដោយមិនត្រូវបង្កើតឱ្យមានរចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងអចិន្ត្រៃយ៍ថ្មីដែលនាំឱ្យបង្កើនបន្ទុកចំណាយថវិកាឡើយ។

# ជំពូកទី៤
# គណនេយ្យភាពនិងការទទួលខុសត្រូវក្នុងការគ្រប់គ្រង និងចាត់ចែងមុខតំណែងក្នុងមុខងារសាធារណៈ

**មាត្រា១០ .-**

មន្ត្រីរាជការស៊ីវិលទាំងអស់ដែលកំពុងកាន់មុខតំណែងគ្រប់គ្រងនិងកំពុងបំពេញការងារនៅតាមក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ត្រូវទទួលបានការបែងចែកនិងការកំណត់មុខងារនិងភារកិច្ចច្បាស់លាស់ ដើម្បីគាំទ្រដល់បេសកកម្មនិងមុខងាររបស់ក្រសួង ស្ថាប័ន។

ក្រសួង ស្ថាប័ន និងអង្គភាពទាំងឡាយនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិដែលមិនមានធ្វើការបែងចែកនិងការកំណត់មុខងារនិងភារកិច្ចច្បាស់លាស់ដល់មន្ត្រីរាជការដែលកាន់មុខតំណែងគ្រប់គ្រងនិងមន្ត្រីរាជការដែលបំពេញការងារក្នុងក្រសួង ស្ថាប័ន និងអង្គភាពរបស់ខ្លួន មិនត្រូវបានអនុញ្ញាតឱ្យធ្វើការជ្រើសរើសមន្ត្រីរាជការក្របខណ្ឌថ្មី មន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែតក្នុងឆ្នាំនីមួយៗឡើយ ទោះបីមានឥណទានថវិកាគ្រោងទុករួចក៏ដោយ។

**មាត្រា១១ .-**

ប្រធានស្ថាប័ន ត្រូវលើកសំណើស្តីពីការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់មុខតំណែងមន្ត្រីរាជការចាប់ពីថ្នាក់ប្រធាននាយកដ្ឋានឡើង ជូននាយករដ្ឋមន្ត្រីពិនិត្យនិងសម្រេច ដោយភ្ជាប់មកជាមួយនូវសេចក្តីព្រាងព្រះរាជក្រឹត្យនិងអនុក្រឹត្យ តាមរយៈក្រសួងមុខងារសាធារណៈ ដែលមានភារកិច្ចពិនិត្យនិងផ្ទៀងផ្ទាត់សំណើនេះ ដោយអនុលោមបទប្បញ្ញត្តិជាធរមាន។

ក្រសួងមុខងារសាធារណៈ ត្រូវរៀបចំឯកសារពាក់ព័ន្ធសំណើស្តីពីការតែងតាំង ការផ្លាស់ប្តូរ ការបញ្ចប់មុខតំណែងមន្ត្រីរាជការជូននាយករដ្ឋមន្ត្រីក្នុងរយៈពេលយ៉ាងយូរ១០(ដប់)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានសំណើដែលមានឯកសារចាំបាច់និងគ្រប់គ្រាន់ពីក្រសួង ស្ថាប័នសាមី។

ក្នុងករណីក្រសួងមុខងារសាធារណៈ ពិនិត្យឃើញថា សំណើស្តីពីការតែងតាំង ការផ្លាស់ប្តូរ ការបញ្ចប់មុខតំណែងមន្ត្រីរាជការ ត្រូវបានធ្វើឡើងមិនអនុលោមបទប្បញ្ញត្តិជាធរមាន ក្រសួងមុខងារសាធារណៈ ត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរ ដោយមានបញ្ជាក់មូលហេតុច្បាស់លាស់ក្នុងរយៈពេលកំណត់ខាងលើ។

**មាត្រា១២ .-**

ប្រធានស្ថាប័ន ត្រូវបញ្ជូនប្រកាសស្តីពីការតែងតាំង ការផ្លាស់ប្តូរ ការបញ្ចប់មុខតំណែងមន្ត្រីរាជការចាប់ពីថ្នាក់អនុប្រធាននាយកដ្ឋានចុះ មកក្រសួងមុខងារសាធារណៈក្នុងរយៈពេលយ៉ាងយូរ ៧(ប្រាំពីរ)ថ្ងៃបន្ទាប់ពីថ្ងៃចេញប្រកាស ដើម្បីពិនិត្យនីត្យានុកូលភាពនិងបំពេញបែបបទពាក់ព័ន្ធនឹងបៀវត្ស ព្រមទាំងការធានាការអនុវត្តតាមបទប្បញ្ញត្តិជាធរមាន។

ក្នុងករណីពិនិត្យឃើញថា ការតែងតាំង ឬការផ្លាស់ប្តូរ ឬការបញ្ចប់មុខតំណែងមន្ត្រីរាជការខាងលើនេះធ្វើឡើងមិនត្រឹមត្រូវតាមបទប្បញ្ញត្តិជាធរមាន ក្រសួងមុខងារសាធារណៈត្រូវធ្វើរបាយការណ៍ជូននាយករដ្ឋមន្ត្រីពិនិត្យនិងសម្រេច។

**មាត្រា១៣ .-**

មន្ទីរមុខងារសាធារណៈរាជធានី ខេត្ត ត្រូវពិនិត្យនិងផ្ទៀងផ្ទាត់ដីកាស្តីពីការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់មុខតំណែងមន្ត្រីរាជការក្នុងរចនាសម្ព័ន្ធគ្រប់គ្រងថ្នាក់ក្រោមជាតិដែលមានសុពលភាព ផ្អែកលើរចនាសម្ព័ន្ធ មុខតំណែង និងចំនួនមុខតំណែងគ្រប់គ្រងក្នុងរចនាសម្ព័ន្ធអនុលោមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ មុននឹងសម្រេចរៀបចំការផ្លាស់ប្តូរស្ថានភាពរដ្ឋបាលរបស់មន្ត្រីរាជការស៊ីវិលក្នុងតារាងទូទាត់បៀវត្សមន្ត្រីរាជការស៊ីវិល។

ក្នុងករណីមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត ពិនិត្យឃើញថា ដីកាខាងលើមិនស្របនឹងរចនាសម្ព័ន្ធមុខតំណែងនិងចំនួនមុខតំណែងគ្រប់គ្រង មន្ទីរ មិនត្រូវរៀបចំការផ្លាស់ប្តូរស្ថានភាពរដ្ឋបាលរបស់មន្ត្រីរាជការស៊ីវិលក្នុងតារាងទូទាត់បៀវត្សមន្ត្រីរាជការស៊ីវិលឡើយ ហើយត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរជម្រាបជូនប្រធានអង្គភាពសាមី និងចម្លងជូនអភិបាលនៃគណៈអភិបាលរាជធានី ខេត្តពាក់ព័ន្ធក្នុងរយៈពេលយ៉ាងយូរ៧ (ប្រាំពីរ)ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីទទួលបានដីកា ដើម្បីមានចំណាត់ការឱ្យសមស្របតាមបទប្បញ្ញត្តិជាធរមាន។

**មាត្រា១៤ .-**

មន្ត្រីរាជការស៊ីវិលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិដែលមានសមត្ថកិច្ចផ្អែកលើបទប្បញ្ញត្តិនៃអនុក្រឹត្យនេះមិនបានបំពេញដោយត្រឹមត្រូវឬខកខានក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនដោយចេតនាឬអចេតនា ត្រូវចាត់ទុកជាកំហុសនិងការធ្លាំធ្លងក្នុងវិជ្ជាជីវៈដែលត្រូវទទួលទណ្ឌកម្មខាងវិន័យ។

មន្ត្រីរាជការស៊ីវិលពាក់ព័ន្ធខាងលើ ត្រូវទទួលទណ្ឌកម្មខាងវិន័យយ៉ាងហោចក្នុងកម្រិតការផ្លាស់ដោយបង្ខំតាមវិធានការខាងវិន័យនិង/ឬត្រូវលុបឈ្មោះចេញពីតារាងឡើងឋានន្តរស័ក្តិឬថ្នាក់ដោយមិនរាប់បញ្ចូលនូវទោសប្បញ្ញត្តិផ្សេងទៀតដែលច្បាប់បានកំណត់ជាធរមាន។

**មាត្រា១៥ .-**

ក្រសួងមុខងារសាធារណៈ ត្រូវសហការជាមួយក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ចធ្វើការពិនិត្យនិងវាយតម្លៃការអនុវត្តខ្លឹមសារនៃអនុក្រឹត្យនេះនិងរាយការណ៍ជូនរាជរដ្ឋាភិបាលអំពីស្ថានភាពនៃការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងគ្រប់គ្រងនៅតាមក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ និងលើកឡើងអំពីវិធានការកែលម្អបន្ត។

## ជំពូកទី៥
## អន្តរប្បញ្ញត្តិ

**មាត្រា១៦ .-**

ក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិដែលបានតែងតាំងមន្ត្រីរាជការស៊ីវិលឱ្យកាន់មុខតំណែងគ្រប់គ្រងកម្រិតអនុប្រធានឬថ្នាក់ប្រហាក់ប្រហែលលើសពីចំនួនដែលបានកំណត់នៅក្នុងមាត្រា៥នៃអនុក្រឹត្យនេះ ហើយនៅមិនទាន់បានទទួលប្រាក់បំណាច់មុខងារ ត្រូវរក្សានៅដដែលនិងត្រូវរៀបចំផ្តល់ជូនប្រាក់បំណាច់មុខងារតាមកម្រិតនៃមុខតំណែងនោះ។

ការផ្តល់ប្រាក់បំណាច់មុខងារខាងលើ ត្រូវគិតចាប់ពីពេលដែលអនុក្រឹត្យនេះចូលជាធរមានប៉ុណ្ណោះ និងមិនមានអានុភាពប្រតិសកម្មទេ។

ការតែងតាំងដើម្បីជំនួសមុខតំណែងទំនេរដែលមានកំណត់ក្នុងវាក្យខណ្ឌទី១នៃមាត្រា១៦នេះ ប៉ុន្តែលើសចំនួនកំណត់ក្នុងមាត្រា៥នៃអនុក្រឹត្យនេះ មិនត្រូវបានអនុញ្ញាតឡើយ។

**មាត្រា១៧ .-**

ការធ្វើសមាហរណកម្មអង្គភាពណាមួយទៅក្នុងក្រសួង ស្ថាប័នផ្សេងទៀត ហើយមិនទាន់មានការរៀបចំមុខតំណែងថ្មីដល់មន្ត្រីរាជការស៊ីវិលក្នុងអង្គភាពដែលត្រូវធ្វើសមាហរណកម្មនោះ មន្ត្រីរាជការស៊ីវិលនោះនៅតែរក្សាមុខតំណែងនិងបុព្វសិទ្ធិនៃមុខតំណែងពីមុនដដែល។

**មាត្រា១៨ .-**

ក្នុងរយៈពេលយ៉ាងយូរ៣(បី)ខែក្រោយពីអនុក្រឹត្យនេះចូលជាធរមាន គ្រប់ក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ត្រូវរៀបចំចងក្រងរចនាសម្ព័ន្ធគ្រប់គ្រង មុខតំណែងគ្រប់គ្រង និងចំនួនមន្ត្រីនៅតាមមុខតំណែងគ្រប់គ្រងផ្តល់មកក្រសួងមុខងារសាធារណៈឱ្យបានរួចរាល់ ផ្អែកលើតារាងគំរូផ្តល់ដោយក្រសួងមុខងារសាធារណៈ ព្រមទាំងត្រូវចាត់ចែងណែនាំដល់អង្គភាពក្រោមឱវាទនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ឱ្យរៀបចំបែងចែកភារកិច្ចទៅតាមមុខតំណែងនិងភារកិច្ចដល់មន្ត្រីរាជការគ្រប់រូបនៃអង្គភាពរបស់ខ្លួនឱ្យបានច្បាស់លាស់និងរួចរាល់ ដើម្បីកំណត់បន្ទាត់គណនេយ្យភាពនិងការទទួលខុសត្រូវរបស់មន្ត្រីរាជការស៊ីវិលម្នាក់ៗក្នុងការបំពេញមុខងាររបស់ខ្លួន។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**មាត្រា១៩ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២០ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ